សព្វាកបត្រព័ត៌មាន NEWSLETTER
លេខ: ៤៩ ខែមីនា ឆ្នាំ២០១០
Issue: 49 March 2010
ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH
គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# សន្និសីទសាធារណៈជាលើកដំបូងរបស់សមាគម ជនរងគ្រោះនៃរបបប្រជាធិបតេយ្យ (ក្សេមក្សាន្ត)

## The First Public Conference of The Association of Victims of the Democratic Kampuchea (KsemKsan)

សមាគមជនរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ ឬហៅម្យ៉ាងទៀតថាជា *"សមាគមក្សេមក្សាន្ត"* ត្រូវបានបង្កើតឡើង និងចាប់ដំណើរការជាផ្លូវការហើយ នេះបើយោងទៅតាមសេចក្តីប្រកាសដោយថ្នាក់ដឹកនាំសមាគម នៅឯសន្និសីទសាធារណៈកាលពី ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១០ នៅទីស្នាក់ការរបស់អង្គការវេទិកា មិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។




*ពីឆ្វេងទៅស្តាំ: លោក ប៊ូ ម៉េង, អ្នកបកប្រែ, លោក ជុំ ស៊ីរ៉ាត់ និងលោក ជុំ ម៉ី*

សមាគមជនរងគ្រោះ ដែលជាសមាគមឯករាជ្យមិនចំណុះឱ្យគណបក្សនយោបាយណាមួយ ឬរាជរដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលណាមួយ ត្រូវបានផ្តួចផ្តើម និងចូលរួមដោយជនរងគ្រោះ នៃ របបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស គឺអតីតអ្នករស់រានមានជីវិត ពីមន្ទីរស-២១ ក្នុងនោះមាន លោក **ជុំ ម៉ី** ដែលជាប្រធាន និងលោក **ប៊ូ ម៉េង** ជាអនុប្រធានទី ២ របស់សមាគម។

លោក **ជុំ ស៊ីរ៉ាត់** ដែលជាអនុប្រធានទី១ នៃ សមាគមជនរងគ្រោះ បានគូសបញ្ជាក់យ៉ាងច្បាស់ៗ នៅក្នុងសន្និសីទសាធារណៈនាពេលនោះថា សមាគមក្សេមក្សាន្ត គឺជាសមាគមជនរងគ្រោះមួយ ដែលត្រូវបានបង្កើតជាលើកដំបូង នៅក្នុងប្រទេសកម្ពុជា។ គោលបំណងនៃការបង្កើតសមាគមនេះ គឺដើម្បីញ៉ាំងឱ្យសំលេងរបស់ជនរងគ្រោះមានភាពរន្ទឺ សម្រាប់ការពារផលប្រយោជន៍របស់ពួកគេ។ គំនិតផ្តួចផ្តើមបង្កើតសមាគមនេះ គឺបានផុសចេញឡើង នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីសម្រេច នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ មិនមានសិទ្ធិចោទសួរ ជនជាប់ចោទ **ឌុច** និងសាក្សីអត្តចរិករបស់ជនជាប់ចោទរូបនេះ ហេតុនេះហើយបានជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះបានតវ៉ាទៅលើសេចក្តីសម្រេចនេះ និងបានធ្វើពហិការមិនចូលរួមក្នុងនីតិវិធីសាលាដំបូងនេះ។

លោក**ជុំ ស៊ីរ៉ាត់**បានគូសបញ្ជាក់បន្ថែមទៀតថាសមាគមនេះ ត្រូវបានចុះបញ្ជីទទួលស្គាល់ពីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១០ និងបានដាក់ពាក្យសុំជាផ្លូវការ និងទទួលស្គាល់ដោយអង្គភាពជនរងគ្រោះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ បន្ទាប់ពីសមាជិកស្ថាបនិក ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០១ និង ០០២ ចំនួន ៣៣រូប បានជួបប្រជុំ នឹងបានសម្រេចចងក្រងបង្កើតជាសមាគមជនរងគ្រោះ នេះឡើង។ បច្ចុប្បន្ននេះ សមាគមក្សេមក្សាន្ត មានសមាជិកដែលជាជនរងគ្រោះមានចំនួន៤៥១នាក់ ក្នុងនោះ មានបុរសចំនួន១២៦នាក់ និងស្ត្រីចំនួន ៣២៥នាក់ ក្នុងនោះដែរក៏មានខ្មែរឥស្លាមចំនួន៦៦នាក់។

នៅក្នុងទិវាសន្និសីទសាធារណៈនោះដែរ ថ្នាក់ដឹកនាំសមាគមបានបង្ហាញនូវជំហរ ក៏ដូចជាសំណូមពរចំនួន ៣ ចំណុចដែលមានដូច ខាងក្រោម:

១- **អភិរក្សឆ្អឹងនៅទួលស្លែង ជើងឯក និងមន្ទីរឃុំឃាំងដទៃផ្សេងទៀត** ដោយមិនត្រូវដុតកំទេចចោលនោះទេ ពីព្រោះសមាគមសង្ឃឹមថា នៅថ្ងៃខាងមុខ នឹងអាចមានបច្ចេកទេសរក DNA នៃក្រុមគ្រួសារសាច់ញាតិនៃឆ្អឹងទាំងនោះ ជាមួយនឹងក្រុមគ្រួសាររបស់គេដែលនៅរស់នាពេលបច្ចុប្បន្ននេះបាន។ ម្យ៉ាងទៀត ការក្សាទុកឆ្អឹងទាំងនេះ ក៏អាចផ្តល់ឱកាសដល់សាច់ញាតិ ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតទាំងនោះរៀបចំពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធបានផងដែរ។

២- **សាងសង់ស្តូបរំលឹក ដែលមានចារឈ្មោះជនរងគ្រោះ**

**ចំនួនប្រមាណជា ១៧០០០ នាក់** ដែលបានទទួលរងទារុណកម្ម និងត្រូវបានសម្លាប់នៅមន្ទីរ-២១ (ទួលស្លែង) និងជើងឯក។ ម្យ៉ាងទៀតសមាគមក៏យល់ស្របតាមទំរង់នៃសំណូមផ្សេងទៀត បានស្នើសុំទៅអង្គសវនាការសាលាដំបូងនៅក្នុងអំឡុង ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កាត់សេចក្តីជនជាប់ចោទ **ឌុច** ដែលបានស្នើឡើងដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

៣- **រៀបចំធ្វើពិធីបួងសួងរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះ នៅថ្ងៃ ប្រកាសសាលក្រម ឌុច នៅសារមន្ទីរទួលស្លែង និងជើងឯក** នៅមុននឹងពេលដែលជនរងគ្រោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿងនេះ និងដែលជាសមាជិករបស់សមាគម ទៅចូលរួមនៅក្នុងសវនាការប្រកាសសាលក្រមនោះ។

ជាមួយនឹងការបង្កើត និងចាប់ដំណើរការ នាពេលនេះថ្នាក់ដឹកនាំសមាគមទាំងអស់ សុទ្ធតែបង្ហាញនូវសុឆន្ទៈធ្វើការសម្រាប់ការពារផលប្រយោជន៍របស់សមាជិកសមាគម ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម។ ដូចនេះ ប្រសិនបើជនរងគ្រោះផ្សេងទៀតមានបំណងចូលរួមជាសមាជិកសមាគម ក៏អាចចូលរួមបានដែរ ដោយតំរូវឱ្យមានការចូលរួមចំណែកបង់វិភាគទានសមាជិកតិចតួច ដើម្បីជួយទ្រទ្រង់សមាគមនេះ ឱ្យមានអត្ថិភាព និងដំណើរការទៅមុខបាន។ ឆ្លៀតក្នុងឱកាសនោះដែរ ថ្នាក់ដឹកនាំសមាគមជនរងគ្រោះ ក៏បានអំពាវនាវឱ្យមានការចូលរួមវិភាគទានពីសប្បុរសជនផ្សេងទៀត ឱ្យបន្តចូលរួមទ្រទ្រង់ក្នុងសកម្មភាពមនុស្សធម៌នេះ។

*ដូចនេះ លោកអ្នក ក៏អាចទំនាក់ទំនងសមាគមក្សេមក្សាន្ត និងជួយគាំទ្រជាវិភាគទានថវិកាសប្បុរសធម៌តាមរយៈ*

| | |
|---|---|
| *លោក ជុំ ម៉ី* | *ប្រធានសមាគម* |
| *លេខទូរស័ព្ទ:* | *០១២ ៧១២ ១៤៨* |
| *Website:* | *www.ksemksan.org* |
| *Email:* | *info@ksemksan.org* |
| *Bank Acc No.:* | *0001106921018* |
| *Account Name:* | *Ksem Ksan Association* |
| | *ACLEDA Bank* |
| *SWIFT Code:* | *ACBKHPP* |
| *CHIPS UID:* | *415637* |
| *ទំនាក់ទំនង:* | *លោក មាស សម្បត្តិ* |
| *អាសយដ្ឋាន:* | *ផ្ទះលេខ ១៥គ ភូមិទ្រា១ សង្កាត់ស្ទឹងមាន ជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។* |

## ថវិកាឆ្នាំថ្មីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអនុម័តរួចរាល់ហើយ

New Budget of ECCC is Officially Approved

តាមប្រភពព័ត៌មានពីមន្ត្រីទំនាក់ទំនងផ្នែកច្បាប់របស់អង្គជំនុំ ជម្រះវិសាមញ្ញ គឺ លោក **ឡាស អូលសិន** ដែលបាននិយាយជាសាធារណៈកាលពីពេលកន្លងមកគួសបញ្ជាក់ថា បញ្ហាគំរោងថវិកា ដែលបានស្នើសុំដោយថ្នាក់ដឹកនាំការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះ ត្រូវបានអនុម័តជាផ្លូវការហើយ ដោយបណ្តារដ្ឋដែលជាសមាជិករបស់អង្គការសហប្រជាជាតិ នៅឯទីក្រុងញូវយ៉ក នៃ សហរដ្ឋអាមេរិកកាលពីពេលថ្មីៗនេះ។ ថវិកាដែលបានស្នើសុំ និងត្រូវបានអនុម័តនេះមានចំនួន **៨៥ លានដុល្លារអាមេរិក** សំរាប់ឱ្យសាលាក្តីខ្មែរក្រហមបន្តកិច្ចប្រតិបត្តិការរបស់ខ្លួនសម្រាប់រយៈពេលពីរឆ្នាំទៀត គឺ ឆ្នាំ២០១០ (ចំនួន ៤២ លានដុល្លារ) និងឆ្នាំ២០១១ (ចំនួន ៤៣លានដុល្លារ)។ ជាមួយនឹងថវិកា ដែលបានអនុម័តជាផ្លូវការនេះ ក៏បានធ្វើឱ្យក្តីបារម្ភអំពីការកាត់សេចក្តីទៅលើមេដឹកនាំខ្មែរក្រហម ដែលកំពុងជាប់ក្នុងមន្ទីរឃុំឃាំងបណ្តោះអាសន្នពេលបច្ចុប្បន្ននេះ ធូរស្រាលមួយកំរិតពីព្រោះថា ទាំងប្រជាជនកម្ពុជាដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម និងទាំងបណ្តាមជ្ឈដ្ឋានអន្តរជាតិដទៃទៀត បាននឹងកំពុងបន្តតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីនេះ។

ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីអ្នកនាំពាក្យរូបនេះ បានកត់សំគាល់បន្ថែមទៀតថា ថវិកាដែលបានអនុម័តរួចហើយនេះ មិនទាន់ត្រូវបានផ្តល់មកឱ្យសាលាក្តីនៅឡើយទេ ដោយសារតែគេត្រូវការពេលវេលាខ្លះដើម្បីរៀបចំការងារជាក់ស្តែងបន្ថែមទៀត ព្រមទាំងធ្វើការកែសម្រួលខ្ទង់ថវិកាមួយចំនួនផងដែរ។

គួរបញ្ជាក់ថា កាលពីពេលកន្លងមក សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានឱ្យដឹងថា មន្ត្រីជាន់ខ្ពស់របស់សាលាក្តីពិសេសនេះ បានធ្វើការស្នើថវិកាបន្ថែមទៀតពី គណៈកម្មាធិការ នៃអង្គការសហប្រជាជាតិ នៅក្នុងកិច្ចប្រជុំមួយនៅឯ បូរីញូវយ៉ក សហរដ្ឋអាមេរិក ដែលមានទឹកប្រាក់ប៉ាន់ស្មានចំនួន**៤៦លាន ដុល្លាសហរដ្ឋអាមេរិកសម្រាប់ឆ្នាំ២០១០ និងចំនួន ៤៧ លាន ៦ សែន ដុល្លារសហរដ្ឋអាមេរិកទៀតសម្រាប់ឆ្នាំ២០១១**។ ថវិកា ដែលបានស្នើសុំនោះ ធ្វើឡើងដោយមានការចូលរួមរបស់មន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះវិសាមញ្ញ គឺឯកឧត្តម **ក្រាញ់ តូនី** ប្រធានស្តីទីការិយាល័យរដ្ឋបាល (ភាគីកម្ពុជា) និង លោក **នុត រូសាន់ហាក់** អនុប្រធានការិយា

ល័យរដ្ឋបាល (ភាគីអន្តរជាតិ)។ ជាក់ស្តែង សម្រាប់រយៈពេលពីរឆ្នាំនេះ ថវិកាដែលបានស្នើសុំនោះ ត្រូវបានបែងចែកជាពីរភាគ គឺមួយភាគសំរាប់ភាគីកម្ពុជា និងមួយភាគទៀត សំរាប់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ។ ក្នុងនោះ ភាគីកម្ពុជាត្រូវការថវិកាចំនួន ១១ លានដុល្លារ សំរាប់ឆ្នាំ២០១០ និង ១១លាន ៨សែនដុល្លារ ទៀត សំរាប់ឆ្នាំ២០១១ ខណៈពេលដែលភាគីអន្តរជាតិ នៃ សាលាក្តីត្រូវការ ៣៤លាន ៥សែនដុល្លារ សំរាប់ឆ្នាំ២០១០ និង ៣៥ លាន ៦សែនដុល្លារ ទៀត សំរាប់ឆ្នាំ២០១១។

ទាក់ទិននឹងបញ្ហាកង្វះថវិកាកន្លងមករបស់សាលាក្តី តែងតែចោទជាក្តីកង្វល់ក្នុងចំណោមសាធារណជនជាទូទៅ។ បន្ថែមលើសពីនេះទៀត ការចោទប្រកាន់អំពីអំពើពុករលួយនៅក្នុងភាគីកម្ពុជារបស់ សាលាក្តីនេះនាពេលកន្លងមក ក៏មិនដឹងជាត្រូវបានដោះស្រាយយ៉ាងដូចម្តេចទៅហើយនោះទេ បើទោះបីជានៅពេលកន្លងមក មានការតស៊ូមតិ និងការចរចាឱ្យមានអ្នកត្រួតពិនិត្យឯករាជ្យ និងយន្តការកំចាត់អំពើពុករលួយជាយថាហេតុក៏ដោយ។ ដូចនេះ យើងទាំងអស់គ្នា ដែលជាសង្គមស៊ីវិល និងប្រជាពលរដ្ឋកម្ពុជាមានសេចក្តីត្រេកអរដែលថា ថវិការបស់សាលាក្តីត្រូវបានគាំទ្រជាបន្តបន្ទាប់ ប៉ុន្តែទន្ទឹមនឹងនេះ យើងក៏ទទូចឱ្យមានការប្រើប្រាស់ថវិកាទាំងនោះឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្នុងបុព្វហេតុបំពេញបេសកកម្មស្វែងរកយុត្តិធម៌ជូនជនរងគ្រោះកម្ពុជា ដែលបានកំពុងតែទន្ទឹងរង់ចាំអស់រយៈពេលដ៏យូរមកនោះ។

## បញ្ហាប្រឈមមួយចំនួនទាក់ទិននឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២

## Current Challenges Related to Civil Party Applicants in Case 002

នៅខណៈពេលដែលសំណុំរឿង០០១ ធ្វើឡើងប្រឆាំងនឹងជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** អតីតប្រធានមន្ទីរស-២១ ត្រូវ បានអង្គជំនុំជម្រះសាលាដំបូង បានបញ្ចប់ការកាត់សេចក្តីរួចរាល់ និង កំពុងរង់ចាំការចេញសាលក្រម ដែលអាចត្រូវបានប្រកាសនៅអំឡុងពាក់កណ្តាលឆ្នាំ២០១០ ខាងមុខ និងសំណុំរឿង០០២ ដែលទើបតែត្រូវបានបញ្ចប់ការស៊ើបអង្កេតរួចរាល់ ហើយរង់ចាំការចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ប្រឆាំងនឹងជនត្រូវ ចោទ ៤រូបទៀត គឺ នួន ជា, អៀង សារី, ខៀវ សំផន និងអៀង ធីរិទ្ធ នៅមានបញ្ហាជាច្រើន ដែលកំពុងប្រឈមយ៉ាងខ្លាំងចំពោះមុខហើយ ដែលត្រូវចាំបាច់ចាត់វិធានការជាបន្ទាន់ពីសំណាក់ភាគីសំខាន់ៗរបស់អង្គជំនុំជម្រះវិសាមញ្ញនេះផងដែរ។

**បញ្ហាទី១: ការដាក់បញ្ជូនព័ត៌មានដែលខ្វះសំរាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំរាប់សំណុំរឿង០០២ ទៅកាន់ការិយាល័យនៃសហចៅក្រមស៊ើបអង្កេត**

កាលពី ថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០១០ ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែល ដឹកនាំដោយលោក ចៅក្រម **យូ ប៊ុនឡេង** (ខ្មែរ) និងលោកចៅក្រម **ម៉ាកសែល ឡឺម៉ុងដ៍** (អន្តរជាតិ) បានចេញសេចក្តីប្រកាសព័ត៌មានអំពីពេលវេលាឈប់ទទួលយកនូវព័ត៌មានបន្ថែម ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ យ៉ាងយូរនៅត្រឹម **ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១០**។ ដូចនេះ អ្នកដាក់ពាក្យសុំទាំងឡាយណា ដែលមានព័ត៌មានមិនទាន់គ្រប់គ្រាន់នៅក្នុងទំរង់ព័ត៌មាន (ឧទាហរណ៍: ខ្វះប័ណ្ណសំគាល់អត្តសញ្ញាណ, ឈ្មោះ, ឈ្មោះទីកន្លែង, ព័ត៌មានអំពីឧក្រិដ្ឋកម្មមិនទាន់គ្រប់គ្រាន់ ។ល។) ត្រូវជួយបំពេញព័ត៌មានបន្ថែមទាំងនោះ ហើយបញ្ជូនទៅកាន់**អង្គភាពគាំពារជនរងគ្រោះ** ដែលមានអាសយដ្ឋាននៅ *ផ្ទះលេខ ៦អា ផ្លូវលេខ ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬ តាមរយៈ លេខទូរស័ព្ទ ០២៣ ២១៤ ២៩១*។

ទាក់ទិននឹងបញ្ហានេះ មន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានពន្យល់ថា**ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**មានលក្ខណៈពិសេសជាង**បណ្តឹងធម្មតា** បើទោះបីជាត្រូវបានដាក់ប្តឹងដោយជនរងគ្រោះនៃរបបខ្មែរក្រហមក៏ដោយ ពីព្រោះថា ប្រសិនបើ ជនរងគ្រោះ ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីហើយ គាត់ត្រូវបានអនុញ្ញាតឱ្យចូលរួមផ្ទាល់នៅក្នុងសំណុំរឿង ០០២ ព្រមទាំងមានសិទ្ធិមួយចំនួនទៀតដូចជា: សិទ្ធិមានមេធាវីតំណាង, សិទ្ធិចោទសួរជនជាប់ចោទ និងសិទ្ធិទាមទារសំណងជាដើម។ ដូចនេះហើយ ដើម្បីឱ្យមានទទួលស្គាល់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះ អ្នកដាក់ពាក្យសុំត្រូវតែបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលកំណត់ដោយវិធានផ្ទៃក្នុង និងសហចៅក្រមស៊ើបអង្កេត។ ការកំណត់រយៈពេលថ្មីនេះ ក៏មិនមែនសំរាប់ការទទួលពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿង០០២នោះទេ ពីព្រោះថា កាលបរិច្ឆេទឈប់ទទួលពាក្យបណ្តឹងនេះតាំងពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០ មកម្ល៉េះ។

**បញ្ហាទី២: ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី**

អង្គភាពគាំពារជនរងគ្រោះ បានបង្ហាញតួលេខ (ត្រឹមថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១០) ទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះដាក់ពាក្យបណ្តឹង នាពេលកន្លងមកថា ពាក្យបណ្តឹងទទួលបានទាំងអស់ មានចំនួន៨,២០២ ក្នុងនោះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋ

ប្បវេណី មានចំនួន៤០០៤ ហើយមានជាង៣០០នាក់ ត្រូវបានទទួលស្គាល់ជាផ្លូវការរួចហើយសំរាប់សំណុំរឿង០០២ (រាប់បញ្ចូលទាំងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់សម្រាប់សំណុំរឿង០០១រួចហើយដែរ) ខណៈពេលដែលមានពាក្យបណ្ដឹងជិត២០០០ទៀត នឹងត្រូវផ្ញើទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូចនេះដើម្បីឱ្យកិច្ចការនេះទាន់ពេលវេលា គឺវាចាំបាច់ឱ្យមានការចូលរួមសហការគ្នារវាង ភាគីពាក់ព័ន្ធរបស់តុលាការ ជាពិសេសអង្គភាពគាំពារ ជនរងគ្រោះ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានជួយគាំទ្រការចូលរួមរបស់ជនរងគ្រោះ ពេលកន្លងមក (សមាគមអាដហុក, វិទ្យាស្ថានខ្មែរដើម្បី លទ្ធិប្រជាធិបតេយ្យ, មជ្ឈមណ្ឌលឯកសារកម្ពុជា, អង្គការក្រុមអ្នក ច្បាប់ការពារសិទ្ធិកម្ពុជា, អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា, សមាគម មេធាវីគ្មានព្រំដែនប្រទេសបារាំង ជាដើម......) បន្តចូលរួមប្រមូលនូវព័ត៌មាន ដែលខ្វះទាំងនេះពីអ្នកដាក់ពាក្យសុំជាដើមបណ្ដឹងរដ្ឋប្បវេណីឱ្យបានទាន់ពេល ដើម្បីធានាថា ពាក្យសុំតាំងខ្លួនផ្សេងទៀតទាំងនោះមានសក្ដានុពល នឹងត្រូវបានទទួលស្គាល់សម្រាប់សំណុំរឿង០០២។

ជាមួយនឹងបញ្ហានេះ មន្ត្រីរបស់សាលាក្ដី បានគូសបញ្ជាក់ថា ប្រសិនបើ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសំរាប់សំណុំរឿង០០២មួយចំនួនណាមួយ មិនត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតទេ នោះ មិនមានន័យថា អ្នកដាក់ពាក្យសុំនោះ មិនមែនជា "*ជនរងគ្រោះ*" នោះទេ ប៉ុន្តែផ្ទុយទៅវិញ សំណុំរឿងរបស់គាត់ត្រូវបានគេចាត់ទុកថាជា "*ពាក្យបណ្ដឹងធម្មតា*" វិញ ហើយត្រូវបានដាក់ចូលធ្វើជាព័ត៌មាននៅក្នុងសំណុំ រឿង០០២ ដដែល។

**បញ្ហាទី៣: ការរកមេធាវីជាតំណាងសំរាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

ការរកមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវតែរៀបចំឱ្យបានមុនពេលដែលសហចៅក្រមស៊ើបអង្កេត នឹងចេញដីកាដំណោះស្រាយ (ប្រហែលជានៅខែកញ្ញា ឆ្នាំ២០១០ ខាងមុខ) ព្រោះ នោះគឺជាការកំណត់នៅក្នុងវិធានផ្ទៃក្នុង ដែលទើបតែត្រូវបានធ្វើកែសំរួលកាលពីខែកុម្ភៈ ឆ្នាំ ២០១០ កន្លងទៅ។ តាមតួលេខរបស់អង្គភាពគាំពារជនរងគ្រោះដដែល ក៏បានបញ្ជាក់ថា មានអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់៤០០៤ មានចំនួន ២,៨០៧ ពាក្យសុំមិនទាន់មានមេធាវីជាតិ និងមេធាវីអន្តរជាតិសំរាប់តំណាងផ្លូវច្បាប់នៅឡើយ ទោះបីជាមានការជួយជ្រោមជ្រែងពីមេធាវីជាតិ និងមេធាវី អន្តរជាតិមកពីអង្គការមិនមែនរដ្ឋាភិបាល (អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា, អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា និងសមាគមមេធាវីគ្មានព្រំដែនប្រទេសបារាំង) និងមេធាវីរបស់តុលាការតំណាងឱ្យអ្នកមួយចំនួនហើយ ក៏ដោយ។ ដូចនេះ វាកាន់តែជំរុញឱ្យខាងសាលាក្ដី និងភាគីពាក់ព័ន្ធទាំងឡាយបន្តធ្វើកិច្ចការនេះតទៅទៀត ដើម្បីឱ្យការចូលរួមរបស់ជនរងគ្រោះ ជាពិសេសនៅក្នុងសំណុំរឿង ០០២ នេះ ទៅមុខដោយរលូន។

**បញ្ហាទី៤: ការបញ្ចូលទិន្នន័យ និង វិភាគពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

ក្រៅពីបញ្ហាប្រឈមមុខខាងលើទាំងនេះ អង្គភាពគាំពារជនរងគ្រោះ ក៏ត្រូវប្រមូលចងក្រង និងវិភាគទិន្នន័យពាក្យបណ្ដឹងទាំងអស់ដែលប្រមូលបាន និងបញ្ជូនទៅកាន់ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតទាន់ពេលវេលាដែរ។ បញ្ហាចោទនៅត្រង់ថា កិច្ចការនេះ វាទាមទារនូវពេលវេលា និងការពិនិត្យយ៉ាងល្អិតល្អន់ដើម្បីជួយធ្វើឱ្យប្រាកដថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ ដែលមកពីមជ្ឈដ្ឋាននានា ទាំងនៅក្នុងប្រទេស និងមកពីក្រៅប្រទេស នឹងត្រូវបានការិយាល័យរបស់សហចៅក្រមស៊ើបអង្កេតធ្វើការឱ្យទាន់ពេលវេលា និងទទួលស្គាល់ជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ មុនពេលចេញដីកាដំណោះស្រាយ។

លើសពីបញ្ហាប្រឈមទាំងនេះ ក៏នៅមានបញ្ហាមួយចំនួនទៀត ដែលត្រូវការឱ្យមានការយកចិត្តទុកដាក់ និងដោះស្រាយជាបន្ទាន់ គឺការរៀបចំឱ្យបណ្ដាញ ឬមធ្យោបាយទំនាក់ទំនងរវាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់គេ (អ្នកតំណាង) ដើម្បីឱ្យការងារទំនាក់ទំនងទាំងឡាយមានភាពងាយស្រួល ពីព្រោះថា ជនរងគ្រោះភាគច្រើនមានទីលំនៅនៅតាមបណ្ដាខេត្តផ្សេងៗ និងការរៀបចំក្រុមនៃក្រុមដើមបណ្ដឹងរដ្ឋប្បវេណីសំរាប់ដំណើរការសវនាការនៅពេលខាងមុខ ព្រមទាំងបញ្ហាថវិកាសំរាប់ប្រតិបត្តិការឱ្យបានពេញលេញ ពីព្រោះថា នៅពេលបច្ចុប្បន្ននេះ បញ្ហានេះនៅមានភាពយឺតយ៉ាវ និងមិនទាន់ច្បាស់លាស់នៅឡើយ។

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ*
*មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ ឌី.អ៊ី.ឌី(**DED**) ទេ។*

**ឧបត្ថម្ភមូលនិធិដោយៈ ឌី.អ៊ី.ឌី**

**ព័ត៌មានសំខាន់:**

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ ហើយចង់សាកសួរព័ត៌មានអំពីសាលាក្ដីខ្មែរ ក្រហមបន្ថែមទៀត

**សូមទាក់ទង:**

- អង្គភាពគាំពារជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១
- ការិយាល័យកិច្ចការសាធារណ: លេខទូរស័ព្ទ: ០១២ ៤៨៨ ១៥៦

➢ ស្ដាប់កម្មវិធីឃ្លាំមើលសាលាក្ដីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញ តាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ **www.krtrial.info**